# កម្ពុជានិងសោកនាដកម្ម

## ឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហមៈ រូបភាព និងសេចក្តីបរិយាយ











### លោក Alexander Goeb

កើតឆ្នាំ១៩៤០ នៅ Dusseldorf ប្រទេសអាល្លឺម៉ង់។ ពីឆ្នាំ ១៩៦៤ ដល់ ១៩៨៣ គាត់គឺ ធ្លាប់ជាអ្នកកែសម្រួលអត្ថបទកាសែត និងទស្សនាវដ្តីជាច្រើន។ បន្ទាប់មកគាត់បានធ្វើជា អ្នកនិពន្ធអត្ថបទ កាសែត និងទស្សនាវដ្តីលក់ដោយខ្លួនឯង ហើយគាត់ធ្លាប់បានទៅ ទស្សនកិច្ចនៅតំបន់ដែលមានជម្លោះជាច្រើនលើពិភពលោក។ នៅឆ្នាំ១៩៧៩ មានតែលោក Goeb ទេដែលធ្វើជាអ្នកសារព័ត៌មាន មកពីសាធារណរដ្ឋសហព័ន្ធ អាល្លឺម៉ង់ អនុញ្ញាតិអោយចូលរួមការកាត់ទោស ប៉ុលពត និង អៀងសារី។ ឆ្លងកាត់រយៈពេលជិត ៣០ឆ្នាំ ហេតុការណ៏នេះបានអភិវឌ្ឍទៅជាកម្មវិធីវិទ្យុសម្រាប់ WDR. គាតបានបោះពុម្ព សៀវភៅមួយក្បាលឈ្មោះថា "កម្ពុជា ដំណើរនៅក្នុងប្រទេសដែលពោរពេញទៅដោយការប៉ះទង្គិចផ្លូវចិត្ត"។ បោះពុម្ពផ្សាយដោយ Brandes & Apsel ២០០៧។

### វណ្ណ ណាត Vann Nath

កើតឆ្នាំ១៩៤៦ នៅខេត្តបាត់ដំបង។ គាត់គឺជានិស្សិតនៅសាលាវិចិត្រសិល្បៈ និងធ្លាប់ធ្វើ ជាវិចិត្រករ និងជាអ្នកលក់រូប។ នៅឆ្នាំ១៩៧៧ គាត់ត្រូវបានគេបំបែកចេញពីគ្រួសារ របស់គាត់ ហើយបញ្ជូនទៅធ្វើទារុណកម្មនៅគុកទួលស្លែងស២១។ ឆ្នាំ១៩៧៩ គាត់បានមករស់នៅជួបជុំប្រពន្ធកូនរបស់គាត់វិញ តែកូនប្រុសគាត់ពីរនាក់ត្រូវបានគេសំលាប់។ វណ្ណ ណាត គឺជាអ្នកជាប់គុកម្នាក់ ក្នុងចំណោមអ្នកជាប់គុក៧នាក់ដែលនៅរស់មានជីវិត ព្រោះគាត់ជាអ្នកគូររូបឱ្យមេដឹកនាំខ្មែរក្រហមប៉ុល ពត។ តាំងពីគាត់មានសេរីភាពនៅឆ្នាំ ១៩៧៩ គាត់បានគូររូបភាពស្តីពីការធ្វើទារុណកម្ម ដែលគាត់ចងចាំ និងបរិយាយស្តីពីអ្នក ជាប់គុកផ្សេងទៀត។ សម្រាប់តុលាការអន្តរជាតិ វណ្ណ ណាត គឺជាជនសំខាន់ម្នាក់ ក្នុងចំណោមជនដែលទទួលទារុណកម្មនៅគុកទួលស្លែង។

### ហេង ស៊ីនិត Heng Sinith

កើតនៅឆ្នាំ១៩៦៨ នៅខេត្តកណ្តាល។ សមាជិកដ៏ច្រើននៅក្នុងគ្រួសាររបស់គាត់បាន ស្លាប់នៅក្នុងរបប ប៉ុល ពត។ ស៊ីនិត បានរួចជីវិតពីការកាប់សម្លាប់ដូចសត្វធាតុ ហើយ នៅឆ្នាំ១៩៨៤ គាត់បានសិក្សានៅវិទ្យាល័យវិចិត្រសិល្បៈនៅទីក្រុងភ្នំពេញ។ នៅឆ្នាំ១៩៩៤ គាតបានសម្រេចចិត្តធ្វើជាអ្នកថតរូប ហើយគាត់ធ្លាប់បានធ្វើការអោយសារព័ត៌មាន កម្ពុជាបីបួនកន្លែងទៀត។ សព្វថ្ងៃនេះគាត់ជាអ្នកថតរូបអោយភ្នាកខ្ញំងារព័ត៌មាន AP។ នៅឆ្នាំ២០០០ លោក ហេង ស៊ីនិត បានជាប់ផ្តើមធ្វើការតាមដានអំពីអតីតខ្មែរក្រហម ឱ្យមជ្ឈមណ្ឌលឯកសារកម្ពុជា។ គាត់បានថតរូបអ្នកដែលទទួលបញ្ជាធ្វើឃាតកម្ម និងធ្វើទារុណកម្ម ហើយសព្វថ្ងៃ គេទាំងអស់នោះនៅមានជីវិតនៅឡើយ និងរស់នៅប្រកប ដោយសេរីភាពពេញលេញនៅក្នុងខេត្តមួយចំនួននៃប្រទេសកម្ពុជា.

# ALEXANDER GOEB VANN NATH HENG SINITH


**Editorial:**
Alexander Goeb
Scheidswaldstr. 6,
60385 Frankfurt am Main-Germany

**Photographs:**
Vann Nath, Heng Sinith,
Youk Chhang, Ea Meng-Try,
Bettina Eichhorn, Alexander Goeb

**Production:**
Mediaproduction Cologne-Germany
www.mediaproductiononline.de

**Sponsoring of the exhibition:**

Hamburger Stiftung zur Förderung von Wissenschaft und Kultur

eed

mediaproduction

# សន្តិភាពនៅប្រទេសកម្ពុជា



កម្ពុជាគឺជាប្រទេសដែលនៅឆ្ងាយ។ ជាប្រទេស ធ្លាប់មានអតីតកាលខ្មៅងងឹត។ ជាប្រទេសដែលពោរពេញ ដោយអាថ៌កំបាំង ប៉ុន្តែក៏ជាប្រទេស មួយដែលពោរពេញទៅដោយស្នាមនិងភាពញញឹមផងដែរ។ ប្រជាជនភាគច្រើនបានស្គាល់ប៉ុលពតថាជាខ្មែរក្រហមជាឧក្រិដ្ឋជនជាឃាតកររួម ដែជាមួយជនដែដល់ដីទៃទៀតបាន សម្លាប់ប្រជាជនស្មើនឹង មួយភាគបួន នៃប្រជាជនប្រាំពីរលាននាក់។ រយៈពេល ៣ឆ្នាំ ៨ខែ ២០ថ្ងៃ គឺជារយៈពេលដែលប្រជាជនកម្ពុជាទាំង អស់មិនអាចបំភ្លេចបាន។ ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៩ គឺជាពេលដែលខ្មែរក្រហម ប្រើអំណាចផ្តាច់ការមកលើប្រជាជនកម្ពុជា។ កាលពីជិត៣០ឆ្នាំមុនខ្មែរក្រហមបានរត់គេចខ្លួនពីកងទ័ពវៀតណាម ឆ្ពោះទៅប្រទេសថៃ។ បន្ទាប់មកសង្គ្រាមស៊ីវិលបានបន្តអស់រយៈពេលវែងជាង ២០ឆ្នាំ។ មេបញ្ញាការមួយចំនួនដែលបានសម្លាប់ប្រជាជនខ្លួនឯង ហើយរួច ជីវិតមកដល់សព្វថ្ងៃនេះ ពួកគេមានវ័យកាន់តែចាស់ទៅហើយ។ អ្នកដ៏ទៃទៀតបានស្លាប់ ព្ត្រូវគេសម្លាប់។ បច្ចុប្បន្នតុលាការមានការយឺតយ៉ាវក្នុងការកាត់ទោសខ្មែរក្រហម ។ ប្រជាជនមានសង្ឃឹមតិចតួចណាស់។















**ទុយ គិន Tuy Kin ទុយ គិន អាយុ៦១ ឆ្នាំ ធ្លាប់ធ្វើជាទាហានខ្មែរក្រហម**

ពីឆ្នាំ ១៩៧០ ដល់ថ្ងៃទី១៧មេសា ឆ្នាំ ១៩៧៥ ជាថ្ងៃរំដោះទីក្រុងភ្នំពេញ ខ្ញុំបានស្គាល់សមរ ភូមិប្រយុទ្ធស្ទើរតែទាំងអស់។ បន្ទាប់មក ខ្ញុំត្រូវបានគេយកទៅដាក់គុកព្រៃស។ ខ្ញុំមិនបានដឹងថាហេតុអ្វីទេ។ នៅទីនោះខ្ញុំ ត្រូវគេបង្ខំអោយធ្វើការ។ បន្ទាប់ពីរបបខ្មែរក្រហម ខ្ញុំក៏បានជាប់គុក ម្តងទៀត។ ខ្ញុំមានកូនម្នាក់ដែលមាន អាយុ៧ខែ។ ប្តីរបស់ខ្ញុំមានប្រពន្ធថ្មីមួយទៀត នៅពេលដែលខ្ញុំមានផ្ទៃពោះ៤ខែ។ ខ្ញុំស្បថថាខ្ញុំមិនបានសម្លាប់ ជនរួមជាតិ ខ្ញុំណាម្នាក់ឡើយ។ បើខ្ញុំនិយាយកុហក ព្រះជាម្ចាស់នឹងដាក់ទណ្ឌកម្មខ្ញុំ។















**ហិម ហុយ Him Huy អាយុ ៥៣ ឆ្នាំ ធ្លាប់ជាប្រធានសន្តិសុខ នៅគុក ស២១**

ការពិតទៅខ្ញុំមិនចង់ធ្វើការនៅទីនេះទេ។ ខ្ញុំបានសួរលោក ស៊ុន សេន ថាតើខ្ញុំ អាចទៅកន្លែងណាមួយផ្សេងទៀតបានទេ។ ប៉ុន្តែគាត់បានបដិសេធ។ មានតែខ្ញុំម្នាក់ ប៉ុណ្ណោះ ដែលហ៊ានសួរសំណួរដូច្នេះ។ ខ្ញុំសួរពីព្រោះខ្ញុំខ្លាចថា បើខ្ញុំនៅទីនេះខ្ញុំ នឹងត្រូវគេសម្លាប់ដែរ។ ខ្ញុំមិនសប្បាយចិត្តទេ នៅពេលដែលឃើញ ប្រជាជន របស់ខ្លួនត្រូវបានស្លាប់ម្តងមួយៗ។ ខ្ញុំចង់ទៅផ្ទះទៅជួបឪពុកម្តាយរបស់ខ្ញុំ។ ប្រជាពលរដ្ឋនៅតែរិះគណៈខ្ញុំ ព្រោះថាខ្ញុំជាបុគ្គលិកនៅគុកទួលស្លែង។ ខ្ញុំមិនបានស្ម័គ្រ ចិត្តធ្វើការនៅទីនោះទេ។ ពួកគេបង្ខំខ្ញុំ អោយធ្វើការនៅក្នុងគុកនោះ។ ប្រសិនបើខ្ញុំបដិសេធពួកគេនឹងសម្លាប់ខ្ញុំភ្លាម។ បើតុលាការកោះហៅខ្ញុំ ខ្ញុំនឹងមិនញញើត ធ្វើជាសាក្សីនូវអ្វី--ដែលខ្ញុំបានធ្វើនៅក្នុងគុក និង ហេតុផលអ្វីដែលខ្ញុំធ្វើវានោះទេ។

















**សួន និម Soan Nim អាយុ ៦០ឆ្នាំ ធ្លាប់ជាប្រធានកងខ្មែរក្រហម**

នៅឆ្នាំ១៩៧៤ ខ្មែរក្រហមជាប់ផ្តើមកៀងកងមនុស្ស អោយចូលបម្រើកងទ័ព។ ខ្ញុំបានស្ម័គ្រចិត្តធ្វើជាកងទ័ព ពីព្រោះខ្ញុំគិតថាវាប្រសើរជាងការងារលើកទំនប់ទឹក និងជីកប្រឡាយ ដូចប្រជាជនធម្មតា ហើយខ្ញុំនឹងទទួលបានហូបចុកគ្រប់គ្រាន់។ ឪពុករបស់ខ្ញុំមិនចង់អោយខ្ញុំធ្វើទេ ប៉ុន្តែខ្ញុំតាំងចិត្តថាខ្ញុំត្រូវតែធ្វើ ពីព្រោះខ្ញុំមិនចង់អោយនរណាមកថាខ្ញុំកំសាកទេ។ ឪពុករបស់ខ្ញុំគឺជាបុរសដែលខ្លាំងបំផុតម្នាក់ ប៉ុន្តែនៅថ្ងៃដែលខ្ញុំចេញទៅ ខ្ញុំឃើញគាត់យំ។ ខ្មែរក្រហមបានបំផ្លាញគ្រួសាររបស់ខ្ញុំ។ នៅក្នុងរបបពួកគេយើងរងទុក្ខយ៉ាងខ្លាំង ពួកយើងឃ្លាន ហើយនិងបែកបាក់គ្រួសារ។ ពួកយើងកម្របាន ជួបគ្នាណាស់។ ខ្ញុំមិនជឿនូវអ្វីដែលពួកគេបានបង្រៀនខ្ញុំទេ ប៉ុន្តែខ្ញុំមិនអាចធ្វើអ្វីបានទាំងអស់ ពីព្រោះគ្រប់គ្នា ស្ថិតនៅក្រោមការតាមដានរបស់ពួកគេ។ ការសង្គ្រោះជីវិតរបស់ពួកយើងគឺពួកយើង ធ្វើតាមអ្វីដែលពួកគេ បង្គាប់ឱ្យធ្វើ។





















**សួស ធី Suos Thy អាយុ ៥៦ឆ្នាំ ធ្លាប់ធ្វើការនៅគុកទួលស្លែងស២១**

នៅឆ្នាំ១៩៧៦ ខ្ញុំបានធ្វើការជាអ្នកចងក្រងឯកសារនៅមន្ទីរស២១។ ខ្ញុំគិតថាពួកគេ តែងតាំងអោយខ្ញុំធ្វើការងារនេះ ពីព្រោះខ្ញុំមានបទពិសោធន៍ក្នុងការសរសេរ។ នៅឆ្នាំ១៩៨៣ ខ្ញុំនៅក្នុងគុកអស់រយៈពេល ៣ឆ្នាំ។ ខ្ញុំគិតថាវាអយុត្តិធម៌ណាស់ ដែលខ្ញុំនៅក្នុងគុក ខណៈពេលដែលមេដឹកនាំខ្មែរក្រហមមានសេរីភាព។ របបកាប់សម្លាប់គឺបានបង្កើតឡើង ដោយពួកគេ ដូច្នេះពួកគេត្រូវតែទទួលខុសត្រូវលើវាទាំងអស់។ ខ្ញុំមិនបានព្យាយាមដោះសារ យករួចខ្លួននោះទេ។ ពេលដែលខ្ញុំបានឮមេដឹក នាំខ្មែរក្រហមនិយាយថា ពួកគេមិនបានដឹងឮអ្វីៗទាំងអស់អំពីអត្ថិភាពរបស់គុកទួលស្លែងនោះ ខ្ញុំអស់សំណើច មែនទែន។ វាគឺជាគុកដែលធំមួយ មិនមែនជាគុកដែល តូចតែមួយនោះទេ ហើយអ្នកដែលបង្កើតគុក នេះពិតជាអ្នកមានតួនាទីយ៉ាងសំខាន់នៅក្នុងសម័យធ្វើបដិវត្តន៍។ អ្នកជាប់ទោសមកពីគ្រប់ទីកន្លែងនៅក្នុងប្រទេស។ប្រាកដណាស់ថាមេដឹកនាំទាំងអស់បាននិយាយកុហកពួកយើង។












**មាស ផេងគ្រី Meas Pengkry អាយុ៥២ឆ្នាំ ធ្លាប់ជាទាហានខ្មែរក្រហម**

ខ្ញុំបានឃើញទាំងពេលវេលាដែលល្អ និងពេលវេលាដ៏អាក្រក់ក្នុងរបបខ្មែរក្រហម។ ខ្ញុំនឹង ប្រាប់កូនៗខ្ញុំថានៅជំនាន់ ប៉ុល ពត ប្រជាជនត្រូវបង្ខំអោយធ្វើការដោយគ្មានពេលសម្រាក ហើយការហូបចុកតិចតួចណាស់។ ប្រជាជនហូបគ្រប់យ៉ាងដែលពួកគេអាច ហូបបាន ពួកគេបានស្វែងរកដូចជាស្លឹកឈើ និងមើមឈើធ្វើអាហារ។ បច្ចុប្បន្ននេះ ខ្ញុំបានដាស់តឿនកូនរបស់ខ្ញុំអោយធ្វើការអោយបានច្រើន យើងនឹងមានការងារដែលល្អ សម្រាប់ខ្លួនយើង ។ បើយើងមិនជួយខ្លួនយើងទេ គ្មាននរណាម្នាក់ជួយយើងឡើយ។











**ឡូ ស៊ីម Lo Sim អាយុ ៥៥ឆ្នាំ ធ្លាប់ជាមេកងខ្មែរក្រហម**

ខ្ញុំមិនដឹងនិយាយអ្វីអំពីមេដឹកនាំខ្មែរក្រហមទេ។ ពួកគេឃោឃៅណាស់ ពួកគេបានសម្លាប់ប្រជាជនខ្លួនឯង។ នៅក្នុងគុកព្រៃស ខ្ញុំបានបង្ហាញពីភាពស្មោះត្រង់ និងការស្តាប់បង្គាប់ ហើយខ្ញុំបានធ្វើការយ៉ាងធ្ងន់ធ្ងរដើម្បីអោយរួចជីវិត។ រាល់យប់ មនុស្សបួនទៅប្រាំនាក់ត្រូវបានគេយកទៅ ស ម្លាប់។ គេបានប្រាប់អ្នកទាំងនោះថា ពួកគេត្រូវធ្វើការ ឆ្ងាយ ពីគុក ត្រូវទៅបកផ្លែគ។ ប៉ុន្តែវាមិនពិតទេ ពួកគេទាំងនោះត្រូវគេយកទៅសម្លាប់។










**ញែប ហូ Nheb Ho អាយុ ៥៧ឆ្នាំ ធ្លាប់ជាមេកងខ្មែរក្រហម**

មេដឹកនាំខ្មែរក្រហមទាំងអស់ដែលនិយាយថាពួកគេមិនបានដឹងពីអត្ថិភាពរបស់គុកទួលស្លែងនោះ គឺពួកគេគ្រាន់តែព្យាយាមដោះសារការពារខ្លួនរបស់ពួកគេប៉ុណ្ណោះ ព្រោះថាពួកគេទាំងអស់ធ្វើការជាមួយ ប៉ុល ពត ដែលជាអ្នកបង្កើតគុកដែលមាន ទំហំដល់ទៅមួយគីឡូម៉ែត្រក្រឡានេះ។ លោកមិនគួរគាត់ទោសអ្នកតូចតាច ហើយបិទបាំង បទឧក្រិដ្ឋរបស់ពួកគេទេ នេះវាអយុត្តិធម៌ណាស់។ ប្រជាជននៅក្នុងភូមិបានហៅខ្ញុំថា ជាអ្នកគាំទ្រ ប៉ុល ពត ។ ខ្ញុំមិនដាក់កំហុសទៅលើពួកគេទេ ព្រោះវាគឺជាការពិត ខ្ញុំបានធ្វើការអោយពួកខ្មែរក្រហមមែន។ អ្នកភូមិជាច្រើនបានដឹងថាខ្ញុំបានធ្វើការនៅក្នុងគុកទួលស្លែង។ ខ្ញុំមិនសោកស្តាយទេ ប៉ុន្តែ ខ្ញុំមានអារម្មណ៍អាណិតប្រពន្ធនិងកូនរបស់ខ្ញុំ គាត់ឈឺជាប់នៅពេលដែលមនុស្សទាំងអស់ និយាយពីខ្ញុំ។







**នួន ហុង Nuon Hong អាយុ ៤៩ឆ្នាំ ធ្លាប់ជាទាហានខ្មែរក្រហម**

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្ញុំរស់នៅខ្លាចគេយកទៅសម្លាប់។ មនុស្សគ្រប់គ្នាមានការភ័យខ្លាច របៀបនេះដូចៗគ្នា។ រៀងរាល់ពីរបីថ្ងៃម្តងមានរថយន្តដឹកមនុស្សចេញទៅ ឆ្ងាយដោយគ្មានហេតុផល។ ពេលនោះម្នាក់រស់នៅ ពោរពេញដោយភាពភ័យខ្លាចមានកំហុស គេយកទៅសម្លាប់។អ្នកជាប់គុកគឺមានស?ណាងតិចតួចណាស់ ថាអាចរួចខ្លួន។











**អ៊ឹម ចន្ថា Im Chanta អាយុ ៥២ឆ្នាំ ធ្លាប់ជាទាហានខ្មែរក្រហម**

នៅក្នុងគុកព្រៃសខ្ញុំបានបាត់កាំបិតមួយ។ សហាសេរិកខ្ញុំបានលាក់កាំបិតនេះ។ ពេលនោះ មេរបស់ខ្ញុំបានវាយតប់ខ្ញុំជាមួយនឹងដំបង។ មេដឹកនាំខ្មែរក្រហមគួរតែប្រហារជីវិតសម នឹងអំពើឃាតកម្មដ៏ឃោរឃៅ របស់ពួកគេមកលើប្រជាជន និងដោយសារពួកគេធ្វើអោយខ្ញុំឈឺចាប់។



# អ្នកប្រព្រឹត្តិបទឧក្រិដ្ឋ







**អៀង សារី Ieng Sary គឺជាបងធំទី៣** ហើយជាមិត្តស្និទ្ធស្នាលរបស់ ប៉ុល ពត។ គាត់កើតនៅវៀតណាមខាងត្បូង ក្នុងខេត្ត វិន ឡុង មានឈ្មោះថា គឹម ត្រាង។ ឆ្នាំកំណើតរបស់គាត់គឺគ្មាននរណាដឹងពិតប្រាកដនោះទេ។ គេនិយាយថាគាត់កើតនៅចន្លោះ ឆ្នាំ១៩២២ និង១៩២៥។ គេក៏ធ្លាប់និយាយពីឆ្នាំ១៩២៩ផងដែរ។ ឳពុករបស់គាត់គឺជា ជនជាតិវៀតណាម ម្តាយរបស់គាត់គឺជាខ្មែរកម្ពុជាក្រោម។ គេតែងហៅជនជាតិភាគតិចខ្មែរដែលរស់នៅវៀតណាមខាងត្បូងដូច្នេះ។ ឳពុកម្តាយរបស់គាត់គឺជាគ្រួសារមាន និង មានកាន់កាប់ដីធ្លីទៀតផង។ ក្រោយមក អៀង សារី បានព្យាយាមបិទបាំង មិនអោយនរណាដឹងពីកំណើតរបស់គាត់ ជាវៀតណាមទេ។ គាត់បានរៀននៅសាលាលិសេស៊ីសុវត្ថិ បន្ទាប់មកទៅទីក្រុងប៉ារីស៍រៀននៅសាលាពាណិជ្ជកម្មមួយ ក្នុងឆ្នាំ១៩៥០។ នៅទីនោះ គាត់បានក្លាយទៅជាប្រធានសមាគមនិស្សិតខ្មែរនៅឆ្នាំ១៩៥៥ ហើយបានត្រឡប់ទៅធ្វើជាគ្រូបង្រៀននៅសាលាលិសេ ស៊ីសុវត្ថិ នៅឆ្នាំ១៩៥៧។ ដូចជា ប៉ុល ពត ដែរគាត់បានភៀសខ្លួនទៅនៅក្នុងព្រៃ ក្នុងឆ្នាំ ១៩៦៣។

**ខៀវ សំផន Khieu Samphan** កើតនៅឆ្នាំ ១៩៣១ នៅខេត្តស្វាយរៀង ជាកូនប្រុសរបស់មន្ត្រីរាជការតូចតាចម្នាក់។ នៅឆ្នាំ១៩៥៤ គាត់បានទៅទីក្រុងប៉ារីស៍ ហើយបានសិក្សារៀនសូត្រផ្នែកច្បាប់និងសេដ្ឋកិច្ច។ នៅឆ្នាំ១៩៥៩ គាត់បានទទួលសញ្ញាប័ត្រ ថ្នាក់បណ្ឌិត ក្រោមប្រធានបទ "សេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា និង បញ្ហាឧស្សាហូបនីយកម្ម "។ បន្ទាប់ពីគាត់ត្រឡប់មកពីទីក្រុងប៉ារីស៍វិញ ជាដំបូង គាត់បានបោះពុម្ពផ្សាយកាសែតមួយច្បាប់ បន្ទាប់មក ត្រូវបានគេជាប់ខ្លួន។ ខៀវសំផន បានបង្រៀននៅសាលាល្បីល្បាញមួយនៅទីក្រុងភ្នំពេញគឺសាលាលិសេស៊ីសុវត្ថិ។ ការបត់បែនរបស់ ខៀវ សំផន បានធ្វើឱ្យខ្លួនជាមនុស្សមួយ គេគោរពកោតខ្លាចក្នុងក្រុមខ្មែរក្រហម។ គាត់បានដឹកនាំធ្វើការបោះបោលក្នុងខេត្តបាត់ដំបងនាឆ្នាំ១៩៦៧។ ពេលនោះ លទ្ធិឆ្វេងនិយម និងលទ្ធិកុម្មុយនិស្ត ត្រូវបានគេរិះគណ:។ អ្នកចូលរួមគឺសុទ្ធតែ ជាកសិករនៅតាមតំបន់ ធ្វើការប្រឆាំងនឹងតម្លៃស្រូវដីថោក និងការដែលទាហានរឹបអូសយកស្រូវ ទាំងបំពាន។ ព្រះអង្គម្ចាស់សីហនុ គឺជាមេដឹកនាំប្រទេសនៅ ពេលនោះបានគំរាមកំហែង ចាប់ប្រជាជន តាមរយៈតុលាការយោធា នឹងការគាត់ទោសប្រហារជីវិត។ ខៀវ សំផន បានសម្រេចចិត្តភៀសខ្លួនចូលទៅក្នុងព្រៃ។













# អ្នកប្រព្រឹត្តិបទឧក្រិដ្ឋ





**នួន ជា Nuon Chea គឺជាបងធំទី២** និងជាអនុរបស់ ប៉ុល ពតដែរ។ គាត់កើតនៅ ខេត្តបាត់ដំបងក្នុងឆ្នាំ ១៩២៧ ដែលមានដើមកំណើត ជាកូនកាត់ថៃចិន។ ប្រហែលចុងកំឡុងឆ្នាំ១៩៤០ គាត់បានធ្វើការនៅ ក្រសួងការបរទេសថៃ។ នៅឆ្នាំ១៩៥១ គាត់បានទៅទីក្រុងហាណូយរយៈពេលបីឆ្នាំ ហើយពេលគាត់ត្រឡប់មកវិញ ក៏បានក្លាយជាជំនួយការលេខាធិកាទូទៅរបស់បក្ស ប្រជាជនបដិវត្តន៏ប្រជាជនកម្ពុជា។ នួន ជា ប្រកាន់ខ្ជាប់ នូវអំណាចផ្តាច់ការនៃខ្មែរក្រហម។ នៅឆ្នាំ១៩៧៥ គាត់មានតួនាទីជានាយករដ្ឋមន្ត្រី មួយរយៈ។ ទស្សនៈរបស់ នួន ជា សម្រាប់អនាគតប្រទេសកម្ពុជា គឺវាជា ភារកិច្ចរបស់ យើងសម្រាប់រយៈពេល១០ឆ្នាំ មួយរយឆ្នាំ មួយពាន់ឆ្នាំ មួយម៉ឺនឆ្នាំ មួយសែនឆ្នាំ ទៅមុខទៀត គឺត្រូវការពារប្រទេសកម្ពុជា សម្ហូហភាព និងកម្មករ កសិករ និងកសាង សង្គមជាតិដោយមហាលោតផ្លោះមហា អស្ចារ្យមួយ។ រហូតដល់ការជាប់ខ្លួនរបស់គាត់ នៅឆ្នាំ ២០០៧ គាត់បានរស់នៅជាកសិករធម្មតា នៅជិតប៉ៃលិន ជាប់ព្រំប្រទល់ប្រទេសថៃ។

**អៀង ធីរិទ្ធ Ieng Tirith** អតីតជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ចខ្មែរក្រហមហើយជា សមាជិកនៃគណៈកម្មាធិការកណ្តាលរបស់គណបក្ស ផងដែរ។ គាត់មានឈ្មោះកំណើតថា ខៀវ ធីរិទ្ធ ជាប្រពន្ធ អៀង សារី។ បងស្រីរបស់គាត់គឺ ខៀវ ពុនណារី ជាប្រពន្ធទីមួយរបស់ ប៉ុល ពត។ អៀង ធីរិទ្ធ គាត់ដើរតួសំខាន់ក្នុងរបបខ្មែរក្រហម។ គាត់បានលើកជើងកម្លាំងយុវជន ជាកម្លាំងស្រួច ហើយបាននិយាយថា យើងមិនត្រូវ ការ-អ្នកដែលមានវ័យចាស់នោះទេ ពីព្រោះពួកគេមិនផ្លាស់ប្តូរគំនិតរបស់ពួកគេបានទេ។













# អ្នកប្រព្រឹត្តិបទឧក្រិដ្ឋ









**កាំង ហ្គិចអៀវ Kaing Guek Eav ហៅឌុច** គឺជាអតីតប្រធានគុកទួលស្លែង ស២១ ពីឆ្នាំ ១៩៧៦។ គាត់បានកើតនៅឆ្នាំ១៩៤២ នៅក្បែរទីក្រុងកំពង់-ធំ។ គាត់មកពីគ្រួសារខ្មែរគាត់ចិន។ មានភាពស្រដៀងគ្នាទៅនឹងមេដឹកនាំខ្មែរក្រហមផ្សេងទៀត គាត់បានសិក្សានៅសាលាលិសេស៊ីសុវត្ថិ។ បន្ទាប់មកគាត់ត្រូវបានគេជាប់ឃុំឃាំង ដូចពួកនិយមលទ្ធិឆ្វេង នៅក្រោមសម័យគ្រប់គ្រងរបស់សីហ-នុ។ គាតបានរត់គេចខ្លួនទៅក្នុងព្រៃ។ ហិម ហ៊ុយ ជាប្រធានសន្តិសុខនៅក្នុងគុកទួលស្លែង ដែលជាអ្នកទទួលបន្ទុក រឿងឃាតកម្មជាង២០០០នាក់ បានអធិប្បាយថា ឌុចគឺជាមនុស្សម៉ត់ចត់ ប៉ុន្តែយុត្តិធម៌ អ្វីដែលគាត់និយាយគាត់ធ្វើ។ នៅកំឡុង ឆ្នាំ១៩៩០ ឌុចបានត្រឡប់ទៅកាន់សាសនាគ្រឹស្ត អេវិនជីលិសវិញ។ នៅឆ្នាំ១៩៩៩ អ្នកសារព័ត៏មានម្នាក់បានសរសេរពីអត្តសញ្ញាណ របស់គាត់។ នៅពេលនោះ ឌុចត្រូវបានគេចាប់ខ្លួន ហើយយកទៅដាក់គុក។ នៅខែ វិច្ឆិកា ឆ្នាំ ២០០៧ គាត់ត្រូវបានគេប្រគល់ទៅអោយតុលាការអន្តរជាតិ។

**ប៉ុល ពត Pol Pot ឈ្មោះពិតគឺ សាឡុត ស** គាត់ជាបងទីមួយដែលគួរអោយញញើតរបស់ពួកខ្មែរក្រហម។ គាត់កើតនៅឆ្នាំ១៩២៨ នៅខេត្តកំពង់ធំ។ ឪពុកម្តាយរបស់គាត់ គឺជាអ្នកមានទ្រព្យសម្បត្តិនិងម្តាយរបស់គាត់គឺជាជនជាតិចិន។ គាត់បានបញ្ចប់ការសិក្សា ពីសាលាមធ្យមបច្ចេកទេសនៅទីក្រុងភ្នំពេញ។ គាត់ក្លាយទៅជាជាងឈើ ហើយនៅឆ្នាំ១៩៤៩ គាត់បានទៅទីក្រុងប៉ារីស៏សិក្សាពីផ្នែកវិស្វករវិទ្យុ។ បន្ទាប់ពីគាត់បានប្រឡងធ្លាក់ ៣ដង គាត់បានត្រឡប់ទៅទីក្រុងភ្នំពេញវិញក្នុងឆ្នាំ១៩៥៣។ នៅពេលនោះគាត់មានការចាប់អារម្មណ៏យ៉ាងខ្លាំងលើផ្នែកនយោបាយ និងអក្សរសាស្រ្តបារាំង។ Verlaine គឺជាអ្នកនៅក្នុងចំណោមអ្នកកវីដែលគាត់ចូលចិត្ត។ ក្រោយមក សាឡុត ស បានបង្រៀននៅសាលា លិសេ កម្ពុជបុត្រ និងបានចូលជាសមាជិកក្រុមឆ្វេងនិយម។ នៅឆ្នាំ១៩៦៣ គាត់បានរត់គេចខ្លួនទៅក្នុងព្រៃ។
អស់រយៈពេលជាច្រើនឆ្នាំគ្មាននរណាម្នាក់ដឹងពីឈ្មោះ ប៉ុល ពត ទេ។ គឺមិនបានដឹងរហូតដល់ឆ្នាំ១៩៧៧ នៅពេលដែលរូបថតរបស់គាត់បានផ្សាយជាសាធារណះនៅក្នុង ប្រទេសចិន។ ពេលនោះគាត់ត្រូវបានគេស្គាល់ថាជា សាឡុត ស។ ប៉ុល ពត បាន ស្លាប់នៅឆ្នាំ១៩៩៨ នៅជិត អន្លង់វែង នៃភូមិភាគឧត្តរ ក្នុងប្រទេសកម្ពុជា។













# THE TRIBUNAL







## តុលាការអន្តរជាតិ

មានឈ្មោះថាអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា បានកើតឡើងដើម្បីបំភ្លឺប្រវត្តិសាស្ត្រប្រទេសកម្ពុជា។ ច្រើនជាងបីបួនទសវត្សហើយ ដែលក្រុមប្រឹក្សាអង្គការសហប្រជាជាតិ មិនយកចិត្តទុកដាក់ចំពោះការស្លាប់របស់ប្រជាជនក្នុងប្រទេសកម្ពុជា។ ចិន និងអាមេរិកបាន ការពាររាល់ការកាត់ទោសឧក្រិដ្ឋជន និងបានព្រមព្រៀងឱ្យខ្មែរក្រហមជាតំណាង កម្ពុជានៅអង្គការសហប្រជាជាតិក្រោយឆ្នាំ១៩៧៩។ ទាំងនេះជាហេតុការណ៏ប្រវត្តិសាស្ត្រ ផងមួយដែរ។ នៅឆ្នាំ១៩៧៥ វៀតណាមតូចមួយបានឈ្នះសង្គ្រាមលើមហាអំណាច អាមេរិក ព្រមទាំងបានរំដោះប្រទេសកម្ពុជាពីរបបដែលគួរអោយខ្លាចប៉ុលពត នេះដែល ទទួលការគ្រាំទ្រពីប្រទេសចិន។ វៀតណាមបានកាន់អំណាចនៅប្រទេសខ្មែររហូតដល់ឆ្នាំ ១៩៨៩។ បន្ទាប់មកមានគំរោងអង្គការសហប្រជាជាតិ ដែលមានតម្លៃមួយរយកោដិក្នុង ឆ្នាំ១៩៩២ ដល់១៩៩៣ ដើម្បីបញ្ចប់សង្គ្រាមស៊ីវិល បញ្ហាជនភៀសខ្លួន និងណែនាំរបប លទ្ធិប្រជាធិបតេយ្យ។ នៅឆ្នាំ១៩៩៧ទើបគណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ

បានថ្លែងសុន្ទរកថាដំបូងចំពោះការកាត់ទោសលើអ្នកទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ ទៅកាត់ទោស។ នៅឆ្នាំ២០០១ សភានៃព្រះរាជាណាចក្រកម្ពុជាបានអនុម័តច្បាប់ក្នុងការបង្កើតអង្គជំនុំជំរះវិសាមញ្ញក្នុងតុ-លាការកម្ពុជា ដើម្បីកាត់ទោសឧក្រិដ្ឋជន ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ នៅខែមិនាឆ្នាំ ២០០៣ មានកិច្ចប្រមព្រៀងគ្នាពីអង្គការ សហប្រជាជាតិ។ ឧសភាឆ្នាំ២០០៣ មហាសន្និបាតអង្គការសហប្រជាជាតិបានធ្វើ សច្ចាប័នសម្រេចបង្កើតតុលាការដែលបានចុះហត្ថលេខា ពីភាគីទាំងសងខាង។ សេចក្ដីសម្រេចចិត្តបានឱ្យតុលាការមានមូលដ្ឋាននៅប្រទេសកម្ពុជា ហើយចៅក្រមភាគច្រើនជា ចៅក្រមកម្ពុជា។ ទោះជាយ៉ាងណាក៏ត្រូវមានចៅក្រមអន្តរជាតិមួយរូបយ៉ាងតិចយល់ព្រម ចំពោះការសម្រេចចិត្តលើមតិភាគច្រើន។

ពីខែសីហា ដល់ខែវិច្ឆិកា ឆ្នាំ២០០៧ មនុស្សបួននាក់ដែលជាមេដឹកនាំខ្មែរក្រហមត្រូវបានចាប់ខ្លួនហើយយកទៅដាក់ក្នុងគុកតុលាការ។ អតីតប្រធានគុកទួលស្លែង ស២១ ឌុច ត្រូវបានគេដាក់គុកតាំងពីឆ្នាំ ១៩៩៩ ហើយក៏ត្រូវបានតុលាការកាត់ទោសផងដែរ។





# វ៉ាន់ ណាត និងការសម្ភាសន៍ជាមួយនឹងឃាតករម្នាក់

**នៅក្នុងអំឡុងឆ្នាំ១៩៩៥** មានទាហានខ្មែរក្រហមមួយចំនួនបានចុះចូលជាមួយនឹងរដ្ឋាភិបាលកាន់អំណាច។ មិត្តភ័ក្តិខ្ញុំម្នាក់បាននិយាយប្រាប់ខ្ញុំថា ហ៊ុយដែលជាអ្នកកាប់សម្លាប់នៅក្នុងគុកទួលស្លែងបានចុះចូលក្នុងជួររដ្ឋាភិបាលនៅក្នុងខេត្តកណ្តាល។ គាត់បានសារភាពថា គាត់បានសម្លាប់មនុស្សអស់ប្រមាណជាង២០០០នាក់។ មិត្តម្នាក់បានបង្ហាញរូបថតរបស់ ហ៊ុយ។

ពេលដែលខ្ញុំមើលឃើញរូបថតនោះខ្ញុំស្គាល់គាត់ភ្លាម។ នៅពេលដែលខ្ញុំស្តាប់ឮថា២០០០ ខ្ញុំគិតថាច្រើនជាង២០០០ទៅទៀត។ គ្រាន់តែនៅឆ្នាំ១៩៧៨គេនាំមនុស្សមកដាក់គុក ទួលស្លែងជាងមួយសែននាក់ឯណោះ។ នៅទីនោះមិនមានទាហានយាមច្រើនទេ ដែលជាអ្នកសម្លាប់អ្នកទោស ពេលនោះ ហ៊ុយត្រូវបានរាប់បញ្ចូលដែរ។ មានន័យថា២០០០នាក់ ដែលគាត់គិតថាគាតបានសម្លាប់ជាចំនួនមួយតូចលើការពិតប៉ុណ្ណោះ។

ក្រោយពេលខ្ញុំឃើញហ៊ុយ ខ្ញុំមាអារម្មណ៍ឈឺចាប់។ ខ្ញុំនឹកឃើញដល់សាកសពជាច្រើន នៅគរលើគ្នាដូចគល់អុស។ ខ្ញុំតែងតែស្រម៉ៃឃើញជានិច្ចនូវទឹកមុខសប្បាយរីករាយរបស់ ពួកអ្នកយាមនៅពេលដែលគេបានឃើញការធ្វើទារុណកម្មមនុស្ស។ វាហាក់ដូចជាមិន ជឿសោះឃាតករដែលបានសម្លាប់មនុស្សរាប់ពាន់ បែរជាមានសិទ្ធិរស់នៅជួបជុំគ្រួសារ ដោយសប្បាយរីករាយទៅវិញ។ ខ្ញុំតែងតែមានជំនឿយ៉ាងមុតមាំថានឹងបានឃើញហ៊ុយ ថ្ងៃណាមួយមិនខាន។ នៅថ្ងៃមួយខ្ញុំបានចូលទៅក្នុងគុក ក្នុងបន្ទប់ដែលខ្ញុំ តែងតែបានគូររូប។ បុគ្គលិកធ្វើការនៅទីនោះម្នាក់បានលួចខ្សឹបប្រាប់ខ្ញុំថា លោកពូនោះអាហ៊ុយ លោកពូ នឹងបានវានៅទីនោះ។

ខ្ញុំឈរពីរម៉ែត្រពីវា បានសម្លឹងមើលវា។ វាមិនបានធ្វើដឹង វាបានគិតថាសំម្លេងខ្ញុំ ហាក់ដូចរសាត់មកពីទីឆ្ងាយ នៅពេលដែលខ្ញុំបាននិយាយទៅរកវា "លោកជាបងហ៊ុយមែនទេ "។ ហ៊ុយបានងាកមុខមករកខ្ញុំហើយបាន ឆ្លើយយ៉ាងស្រួលថា "បាទខ្ញុំនេះហើយ "។ បន្ទាប់មកវាក៏ងាកមុខចេញវិញហើយដើរមើលបន្តទៀត ដោយមិនបានមើលខ្ញុំបន្តទៀតហើយ មិនបានដឹងថាខ្ញុំកំពុងសិឡ្យក់វាទេ។

ស្គាល់ខ្ញុំទេបងប្រុស តបទៅនឹងសំណួរ ខ្ញុំវាបានបែរមករកខ្ញុំ ហើយបានសម្លឹងខ្ញុំយ៉ាងយូរ ហើយ "បានឆ្លើយថា ខ្ញុំមិនស្គាល់លោកទេ"។

"តែខ្ញុំស្គាល់លោកច្បាស់ណាស់ ហេតុអ្វីបានជាលោកមិនស្គាល់ខ្ញុំ? លោកប្រាកដជាប្រធានសន្តិ សុខនៅក្នុងគុកនេះ" ខ្ញុំបាននិយាយដូច្នេះ។ នៅពេលដែលខ្ញុំកំពុងនិយាយ វាបានប្រែទឹកមុខយ៉ាងខ្លាំង។ លោកស្គាល់ខ្ញុំទេ ខ្ញុំជាជាងគំនូរទី៤ក្នុងចំណោមជាងគំនូរ ប្រាំនាក់ដែលធ្វើការនៅក្នុងបន្ទប់នេះ។

និយាយផងខ្ញុំបានបង្ហាញបន្ទប់ដែលខ្ញុំធ្លាប់ធ្វើការផងហើយលោកធ្លាប់មកបន្ទប់នេះជាញឹកញាប់។ នៅពេលនោះខ្ញុំត្រូវបានគេបញ្ជាអោយដឹកអ្នកទោសខ្ញុំត្រូវតែធ្វើតាមបទបញ្ជា វាបាននិយាយដូច្នេះ។ តើលោកបានសម្លាប់មនុស្សអស់ប៉ុន្មាននាក់ ខ្ញុំបានសួរវាដូច្នេះ។

កាលណោះខ្ញុំត្រូវសម្លាប់មនុស្សប្រហែលបួនប្រាំនាក់ ដោយសារខ្ញុំមិនអាចប្រកែកបាន វាបាននិយាយដូច្នេះ។

ខ្ញុំបានអស់សំណើចហួសចិត្ត ហើយបានគិតថាវាមិននៅក្មេងដូចមុនពោរពេញដោយ គំនុំទៀតទេ វាគ្រាន់តែជាមនុស្សម្នាក់ប៉ុណ្ណោះ ប៉ុន្តែបេះដូងនិងវិចារណញ្ញាណរបស់វា មិនមានការប្រែប្រួលអ្វីទេ។ គ្មានសំដីណាមួយរបស់វាជាសំដីពិតនោះទេ។

តាមសារព័ត៌មានខ្ញុំបានដឹងថាលោកបានចុះចូលហើយសារភាពថាបានសម្លាប់មនុស្សជាង២០០០នាក់ តើលោកយល់យ៉ាងដូចម្តេចដែរ? ខ្ញុំបានដាក់សំនួរនេះទៅវា។ វាបានឆ្លើយ ដោយឆ្លាតថា "ជាដំបូងខ្ញុំបានសារភាពការពិត តែបីឬបួនទេ ប៉ុន្តែគេមិនជឿខ្ញុំទេ។ ដូច្នេះហើយបានគិតថា បើខ្ញុំនិយាយថាតែចំនួនតិចនោះគេមិនជឿខ្ញុំទេ ខ្ញុំបានឆ្លើយថា ២០០០តែម្តងទៅពេលនោះគេក៏បានជឿខ្ញុំទៅ។

ខ្ញុំបានគ្រវីក្បាលហើយមានអារម្មណ៍ថាកំពុងចាញ់បោកវា។ ហ៊ុយខ្ញុំគ្មានបំណងអាក្រក់អ្វីទៅលើរូបលោកនោះទេ បើវាដូច្នោះមែននោះ បើមិនដូច្នោះទេនោះ លោកមិនអាចឈរមុខខ្ញុំបានដូចនេះទេ។

ខ្ញុំបានសួរវា តើបានឃើញរូបភាពដែលខ្ញុំបានដាក់តាំងនៅក្នុងមន្ទីរនេះទេ? វាមិនបាន ប្រកែកទេ។

តើលោកយល់យ៉ាងណាដែរចំពោះរូបទាំងនោះ? តើវាមានការគួរពន្លើសដែរឬទេ? ខ្ញុំបាន សួរ។ ទេ រូបនេះមិនគួរពន្លើសទេ ជាយោបល់របស់វា។ មានសកម្មភាពដែលសាហាវ ជាងនេះទៅទៀត។










Photo above left: Nath as a prisoner
Photo down left: Nath in his studio
Photo obove right: Him Huy
Photo down right: prison cell in Tuol Sleng

